# មណ្ឌលវប្បធម៌ខ្មែរនៅស្វីស វត្តសង្ឃារាម

**Khmer Kulturzentrum in der Schweiz**

**Centre Culturel Khmer en Suisse**

Kirchgasse 12, 5746 Walterswil SO / Tel 044 363 59 00 / www.khmer-kulturzentrum.ch




# អាសាឡ្ហបូជា និង ចូលព្រះវស្សា

ព្រះសង្ឃព្រះពុទ្ធសាសនា មិនថាជាតិសាសន៍ណា ឬនៅទីណាឡើយ ឱ្យតែដល់ថ្ងៃ ១ រោច ខែ អាសាឡ្ហ បន្ទាប់ពីពិធីអាសាឡ្ហបូជា ដែលជាបុណ្យដ៏ធំមួយក្នុងព្រះពុទ្ធសាសនាទៅ តែងតែចូលកាន់ព្រះវស្សា សម្ងំស្ងាត់ស្ងៀម ក្នុងកាលកំណត់បីខែតទៅ ។ ដូចនេះហើយ គណៈកម្មការ មណ្ឌលវប្បធម៌ខ្មែរ ក៏បានមូលមតិគ្នាជាឯកច្ឆ័ន្ទ ប្រារព្ធធ្វើបុណ្យ **ចូលព្រះវស្សា** និង **អាសាឡ្ហបូជា** តែមួយជាមួយគ្នា ចំថ្ងៃចូលព្រះវស្សាពិតប្រាកដតែម្តង សម្រាប់ព្រះសង្ឃនៅក្នុងមណ្ឌលវប្បធម៌វត្តខ្មែរយើងផងដែរ ។ អាស្រ័យហេតុនេះ យើងខ្ញុំជាគណៈកម្មការមណ្ឌលវប្បធម៌ខ្មែរនៅស្វីស សូមគោរពអញ្ជើញ ពុទ្ធបរិស័ទញាតិមិត្តបងប្អូនទាំងអស់ ចូលរួមជាមួយយើងខ្ញុំ ដើម្បីបានចំណែកកុសលផលបុណ្យរៀង ៗ ខ្លួន និងញ៉ាំងកម្មវិធីបុណ្យនេះ ឱ្យបានកុះករដោយធម៌កុំបីឃ្លៀងឃ្លាតឡើយ ។

## កម្មវិធីបុណ្យ

ថ្ងៃសៅរ៍ ១ រោច ខែអាសាឡ្ហ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨ ត្រូវនឹងថ្ងៃទី ១២ ខែកក្កដា គ.ស.២០១៤ **(Samstag den 12.07.2014)** នៅមណ្ឌលវប្បធម៌ វត្តខ្មែរ Kirchgasse 12, 5746 Walterswil SO ទូរស័ព្ទ **044 363 59 00** ។

ម៉ោង ១០:00 ជួបជុំពុទ្ធបរិស័ទ

ម៉ោង ១០:៣០ នមស្សការ សមាទានសីល វេរភត្តាហារ ប្រគេនព្រះសង្ឃ។

ម៉ោង ១២:០០ ទទួលទានបាយពេលថ្ងៃត្រង់ជាមួយភ្ញៀវ

ម៉ោង ១៣:៣០ និមន្តព្រះសង្ឃ ចម្រើនព្រះបរិត្ត និង សម្តែងធម្មទេសនា

ម៉ោង ១៥:០០ ធ្វើពិធីអាសាឡ្ហបូជា និងពិធីចូលព្រះវស្សារបស់ព្រះសង្ឃ

